KIDS GOD WORSHIP
www.kidworship.kr

# ចំណេងជើង៖ សាវ័កប៉ុល


120Page

**Narration** លោកសូល គឺជាមនុស្សម្នាក់ដែលបានទទួលការសិក្សាខ្ពង់ខ្ពស់ ប៉ុន្តែគាត់មិនបានស្គាល់ព្រះយេស៊ូឡើយ។ មិនត្រឹមតែប៉ុណ្ណោះ គាត់បានស្អប់និងបៀតបៀនដល់អ្នកណាដែលបានទទួលជឿលើព្រះយេស៊ូថែមទៀតផង។ គាត់តែងតែចាប់អស់អ្នកដែលជឿព្រះយេស៊ូយកទៅដាក់គុក។ លោកសូលបានទៅមហាបូជាចារ្យដើម្បីសុំការអនុញ្ញាត៖

**សូល** សុំមេត្តាចេញលិខិតអនុញ្ញាតមួយសំរាប់ខ្ញុំមក ដើម្បីឲ្យខ្ញុំអាចមានអំណាចនឹងចាប់អស់អ្នកដែលជឿព្រះយេស៊ូ និងនាំពួកគេយកទៅក្រុងយេរូសាឡឹម។


121Page

**Narration** លោកសូលបានចេញដំណើរទៅទីក្រុងដាម៉ាសដើម្បីបៀតបៀន និងចាប់សិស្សរបស់ព្រះយេស៊ូ។

---

**Narration** ប៉ុន្តែនៅពេលដែលលោកសូលបានទៅជិតដល់ទីក្រុងដាម៉ាស់ រំពេចនោះមានពន្លឺមួយបានលេចមកពីផ្ទៃមេឃចាំងមកជុំវិញគាត់។ លោកសូលមិនអាចបើកភ្នែករបស់គាត់បានឡើយ ពីព្រោះពន្លឺនោះវាភ្លឺខ្លាំងពេក។ ទោះបីជាគាត់ខំយកដៃទាំងពីររបស់គាត់មកបាំងមុខក៏ដោយ ក៏គាត់មិនអាចមើលអ្វីឃើញទាល់តែសោះ ព្រោះតែពន្លឺនោះ។ បន្ទាប់មកគាត់បានឮសំលេងមួយចេញពីផ្ទៃមេឃមក។

**ព្រះយេស៊ូ** សូលអើយ, សូល, ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំ?

**សូល** លោកម្ចាស់អើយ! តើលោកជាអ្នកណា?

**ព្រះយេស៊ូ** ខ្ញុំជាយេស៊ូ ដែលអ្នកកំពុងតែបៀតបៀន!


122Page

**Narration** លោកសូលមិនបានជឿថាព្រះយេស៊ូគឺជាស្តេចនៃសាសនយូដាឡើយ ហើយក៏មិនជឿនូវពាក្យសន្យារបស់ព្រះយេស៊ូដែលថាទ្រង់ត្រូវសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញដែរ។


123Page

**ព្រះយេស៊ូ** ដូច្នេះគាត់មានការភ្ញាក់ផ្អើលខ្លាំងណាស់នៅពេលដែល គាត់បានឮព្រះបន្ទូលរបស់ព្រះយេស៊ូ។

**Narration** លោកសូលបានក្រោកឡើងពីដី ទោះបីគាត់ខំប្រឹងបើកភ្នែកយ៉ាងណាដ៏ដោយ ក៏គាត់មើលអ្វីមិនឃើញដែរ។ ដូច្នេះហើយគេបានដឹកដៃគាត់ នាំចូលទៅក្នុងក្រុងដាម៉ាស។

---


124Page

**Narration** ក្នុងរយៈពេលបីថ្ងៃគាត់មិនអាចមើលឃើញ ហើយមិនពិសារបាយពិសារទឹកសោះឡើយ។ ពេលនោះលោកសូលបានកែប្រែចិត្តគំនិតទទួលជឿព្រះយេស៊ូ នឹងអធិស្ឋានទៅព្រះអង្គយ៉ាងអស់ពីចិត្ត។

---

**Narration** នៅពេលនោះ, នៅក្នុងទីក្រុងដាម៉ាស់ មានសិស្សរបស់ព្រះយេស៊ូម្នាក់ឈ្មោះ
អាណាណាស។ ព្រះជាម្ចាស់បានត្រាស់ហៅគាត់នៅក្នុងក្តីនិមិត្តមួយ។

**ព្រះយេស៊ូ** អាណាណាស!  ចូរក្រោកឡើងទៅឯផ្លូវមួយនោះ សួររកឈ្មោះសូល ជាអ្នកស្រុកតើសុស
នៅក្នុងផ្ទះរបស់យូដាស។ ដ្បិតគាត់កំពុងតែអធិស្ឋាន
ដូច្នេះចូរឯងយកដៃរបស់ឯងដាក់លើគាត់ ដើម្បីឲ្យគាត់មើលឃើញឡើងវិញ។

**អាណាណាស** បពិត្រព្រះអម្ចាស់! ទូលបង្គំបានឮមនុស្សជាច្រើននិយាយថាបុរសនេះ
បានធ្វើបាបប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គនៅក្រុងយេរូសាឡឹមខ្លាំងណាស់
ហើយគាត់បានទទួលការអនុញ្ញាតពីលោកមហា បូជាចារ្យអោយមកទីនេះ
ដើម្បីចាប់ចងអស់អ្នកដែលអង្វររកព្រះនាមព្រះអង្គ។

**ព្រះយេស៊ូ** អញ្ជើញទៅចុះ! ដ្បិតខ្ញុំជ្រើសរើសបុរសនេះ
ដើម្បីប្រើគាត់អោយទៅប្រាប់ប្រជាជាតិអ៊ីស្រាអែល អោយស្គាល់ខ្ញុំ។

..........


125Page

**Narration** លោកអាណាណាសក៏ចេញទៅ លុះទៅដល់ផ្ទះនោះ ហើយគាត់ក៏បានឃើញលោកសូល។
គាត់បានដាក់ដៃលើលោកសូល។

**អាណាណាស** បងសូលអើយ! ព្រះអម្ចាស់យេស៊ូដែលបងបានឃើញ
នៅតាមផ្លូវដែលបងបានធ្វើដំណើរមកនោះ ទ្រង់បានចាត់ខ្ញុំឲ្យមក
ដើម្បីឲ្យបងអាចមើលឃើញវិញ និង ឲ្យបងបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

**Narration** បន្ទាប់ពីលោកអាណាណាសគាត់បានអធិស្ឋានហើយភ្លាម។ រំពេចនោះ
មានអ្វីមួយដូចស្រកាត្រី បានជ្រុះចេញពីភ្នែកលោកសូល លោកបានមើលឃើញឡើងវិញ។
លោកសូលបានក្រោកឡើង ហើយទទួលពិធីជ្រមុជទឹក។
លោកសូលក៏ក្លាយទៅជាសិស្សម្នាក់របស់ព្រះយេស៊ូ។

..........


126Page

**Narration** បន្ទាប់មកលោកសូលក៏បានបរិភោគអាហារហើយមានកំលាំងឡើងវិញ។
គាត់បានស្នាក់នៅជាមួយពួកសិស្ស ដែលនៅក្រុងដាម៉ាសបួនដប់ថ្ងៃ។
លោកចាប់ផ្តើមប្រកាសក្នុងសាលាប្រជុំនានាថា ព្រះយេស៊ូជាព្រះបុត្រារបស់

**សូល** ព្រះយេស៊ូគឺជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ចូរទទួលជឿលើទ្រង់ចុះ!!

**បុរស** ថាម៉េច? តើមិនមែនជាលោកនេះទេឬ ដែលបានធ្វើទុក្ខបៀតបៀន
និងចាប់ចងអស់អ្នកដែលអង្វររកឈ្មោះព្រះយេស៊ូ ?

**ស្ត្រី** ជាការពិត! តើរឿងនេះកើត ឡើងបានដោយរបៀបណា? តើនឹងមានអ្វីបន្តទៀត?

**Narration** មនុស្សគ្រប់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង
រីឯលោកសូលវិញលោកមានកំលាំងចិត្តកាន់តែខ្លាំងឡើងៗ
ក្នុងការវែកញែកប្រាប់ឲ្យច្បាស់ថា ព្រះយេស៊ូពិតជា ព្រះគ្រិស្ត។

..........



127Page

**Narration**

យូរថ្ងៃបន្តិចក្រោយមក ជនជាតិយូដាបានសមគំនិតគ្នារកសម្លាប់លោកសូល
តែលោកបានជ្រាបពីគំរោងការរបស់ពួកគេ។
ពួកគេបាននាំគ្នាទៅចាំនៅទ្វាក្រុងទាំងយប់ទាំងថ្ងៃ ដើម្បីសម្លាប់លោក។
ប៉ុន្តែនៅពេលយប់ពួកសិស្សរបស់លោកបានដាក់លោកក្នុងជាលមួយ
សំរូតចុះទៅខាងក្រៅកំពែងក្រុង។ លោកសូលគឺជាអ្នកផ្សាយដំណឹងល្អដ៏ល្បីម្នាក់
ទោះបីលោកប៉ូលបានរងនូវការឈឺចាប់ និងការលំបាកជាច្រើនយ៉ាងណាក៏ដោយ
ក៏គាត់នៅតែតស៊ូប្រកាសពីដំណឹងល្អរបស់ព្រះជាម្ចាស់នៅក្នុងបណ្ដាប្រទេសជាច្រើន។
ផងទៀតនោះលោកប៉ូលបានសរសេរព្រះគម្ពីរ ១៣ខ័ណ្ឌ ក្នុងចំណោមព្រះគម្ពីរទាំង
២៧ខ័ណ្ឌនៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី។